សំណង់ ក្រោមការដឹកនាំរបស់ ឯកឧត្តម ឌុច វន់ទីតូ ហើយមាន សិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ នឹងត្រូវរាយការណ៍ ជូនរាជរដ្ឋាភិបាលលើលទ្ធផលនៃការងាររបស់ខ្លួន ។

**ប្រការ ៤ :**

ក្រុមការងារនេះត្រូវ រំសាយជាស្វ័យប្រវត្តិ នៅពេលដែលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលខេត្តសៀមរាប និងគ្រប់សមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៣៥ សសរ

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ ការប្រព្រឹត្តិទៅ របស់ក្រសួងសុខាភិបាល

-បានទទួល ការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដែលមានឈ្មោះ " គណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ " ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងសុខាភិបាល | | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-អនុរដ្ឋលេខាធិការក្រសួងពត៌មាន | | អនុប្រធាន |
| ៤-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| ៥-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងពាណិជ្ជកម្ម | ០១ រូប | សមាជិក |
| ៦-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១ រូប | សមាជិក |
| ៧-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូប | សមាជិក |
| ៨-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| ៩-អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង នឹងគ្រឿងញៀន | ០១ រូប | សមាជិក |
| ១០-នាយកខុទ្ទកាល័យក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| ១១-ប្រធានមជ្ឈមណ្ឌលជាតិ លើកកំពស់សុខភាព | | សមាជិក និងជាលេខាធិការ |

**ប្រការ ២ :**

គណៈកម្មការអន្តរក្រសួងមានតួនាទី និងភារកិច្ចដូចតទៅ :

១-សំរបសំរួលលើការអង្កេតនិងសិក្សាស្រាវជ្រាវជាអាទិភាព មានជាអាទិ៍ ការអង្កេតលើការប្រើប្រាស់ថ្នាំជក់ និងផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ លើសុខភាព និងសេដ្ឋកិច្ច

២-តាមដាន និងវាយតម្លៃផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

៣-ស្វែងរកការគាំទ្រ និងការចូលរួមពីគ្រប់មជ្ឈដ្ឋានក្នុងការអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ និងជំរុញអោយមានការ ចូលរួមពីស្ថាប័នរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សេវាឯកជន និងសហគមន៍ ដើម្បីអនុវត្តនូវច្បាប់ អនុក្រឹត្យ សារាចរណែនាំ និងការស្រាវជ្រាវសំរាប់ការអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ អោយមានប្រសិទ្ធភាព

៤-រៀបចំពិនិត្យ និងសំរេចនូវសារាចរ សេចក្តីសំរេចណែនាំ និងបទដ្ឋាននានា ស្តីពីការអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ សំរបសំរួលការរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិ សំរាប់អប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ដើម្បីសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

៥-រៀបចំនិងដាក់ស្នើជូនជាសេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងគោលនយោបាយជាតិ ស្តីពីការអប់រំ និងកាត់បន្ថយការ ប្រើប្រាស់ថ្នាំជក់ ជាពិសេសច្បាប់ ឬ អនុក្រឹត្យ ស្តីពីការបង់ពន្ធដារ ការលក់រាយ ការផ្សព្វផ្សាយពាណិជ្ជកម្មការលើកកំពស់សុខភាព ការដាក់ផ្លាកលើផលិតផលថ្នាំជក់ និងការជក់នៅទីសាធារណៈ ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ ៣ :**

បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង តំណាងអោយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ២ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៤ :**

គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយ ដែលមានទីតាំងក្នុងក្រសួងសុខាភិបាល និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាលដើម្បីសំរួលការងារ ។

**ប្រការ ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ជាគណៈកម្មការ ដូចប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

រាជធានីភ្នំពេញ . ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៣៦
## ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់ និង ជាបន្ទាប់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម :